ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៨៣
ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៣
សាលដីកា
លេខ : ១៩៥
ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៤

# តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ០៧ ខែ កញ្ញាឆ្នាំ២០០៤ ដោយមានសមាសភាព ដូចតទៅ

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឌិត** | **មុន្ទី** | ជាប្រធាន |
| ២- លោក | ស៊ិន | ឌីម | ជាចៅក្រម |
| ៣- លោក | ជីវ | កេង | ជាចៅក្រម |
| ៤- លោក | ប្រាក់ | គឹមសាន | ជាចៅក្រម |
| ៥- លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៦- លោក | ប៉ែន | សារឿន | ជាចៅក្រម |
| ៧- លោក | យស់ | សូខឿន | ជាចៅក្រម |
| ៨- លោក | គង់ | គីរុន | ជាចៅក្រម |
| ៩- លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

កញ្ញា ធន់ វណ្ណធឿន

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខលើកទី២ ពីសាលដីការដ្ឋប្បវេណីលេខ ៣៩ " ឃ " ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣១ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៣ របស់

សាលាឧទ្ធរណ៍ រវាង ៖

ដើមចោទឈ្មោះ ម៉ិល សារឿន ចុងបណ្តឹងសាទុក្ខ ភេទ ប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ ទីលំនៅ ផ្ទះលេខ ១៤E០ ផ្លូវលេខ ២៨៧ សង្កាត់បឹងកក់១ ខ័ណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ អ៊ិត ស៊ី " រ " ម្តាយឈ្មោះ អ៊ិន នោ " រ " ប្រពន្ធឈ្មោះ មាស ណារី មានកូន ០២នាក់ ។

និងចុងចម្លើយឈ្មោះ ប៊ូ ភិនសុវណ្ណ ដើមបណ្តឹងសាទុក្ខ ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មុខរបរ យោធា ទីលំនៅផ្ទះលេខ ២៩ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សេក ចាំង " ស " ម្តាយឈ្មោះ កែវ ខឹម " ស " ប្រពន្ធឈ្មោះ ទឹម ស៊្រុន មានកូន ០៦នាក់ ។

អំពីវិវាទ ប្តឹងសុំសិទ្ធិគ្រប់គ្រងដីតាមប័ណ្ណសំគាល់សិទ្ធិលេខ ភព.០០៩៥៥ ចុះថ្ងៃទី ២១-០៨-១៩៩៨ និងឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ រុះរើសំណង់ចេញពីដីនេះ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៨៣ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៣ របស់តុលាការកំពូល ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ២៥៨ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ របស់លោក ប៊ូ ភិនសុវណ្ណ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៩ " យ " ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើត្រង់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ០៧-០២-២០០១ របស់លោក ម៉ិល សារឿន បានប្តឹងសុំសិទ្ធិគ្រប់គ្រងដី តាមប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព ០០៩៥៥ ចុះថ្ងៃទី ២១-០៨-៩៨ ដែលមានទីតាំងស្ថិតនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ និង ទាមទារជំងឺចិត្តចំនួន ៣.០០០ដុល្លា ពីឈ្មោះ ប៊ូ ភិនសុវណ្ណ ដោយអាងហេតុថា ដីនេះខ្លួន បានទិញពីឈ្មោះ ហ៊ុន ប៊ុនធឿន ក្នុងឆ្នាំ ១៩៩៨ ហើយបានធ្វើប័ណ្ណកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែនៅក្នុងឆ្នាំ២០០០ ពេលខ្លួនធ្វើរបងព័ទ្ធដីរបស់ខ្លួន ស្រាប់តែឈ្មោះ ប៊ូ ភិនសុវណ្ណ អះអាងថា ខ្លួនធ្វើរបងចូលដីរបស់គាត់ ទំហំ ៥០ម × ៧៨ម និង បានរុះរើរបងខ្លួនចោលថែមទៀតផង ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ៦០ " ខ " ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០១ របស់តុលាការ ក្រុងភ្នំពេញ ដែលមានខ្លឹមសារ នៃសេចក្តីសំរេចដូចតទៅ ៖

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ម៉ិល សារឿន ចុះថ្ងៃទី ០៧-០២-២០០១ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទទួលស្គាល់ថា ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព.០០៩៥៥ ចុះថ្ងៃទី ២១-០៨-៩៨ របស់ឈ្មោះ ម៉ិល សារឿន នាង មាស ណារី ត្រឹមត្រូវតាមច្បាប់ ដែលក្នុងនោះមានដីទំនាស់ទំហំ ៥៤ម គុណ ៧៨ម ស្មើ ៤.២១២ម$^2$ ផង ។

៣- ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ រុះរើរោងចេញឱ្យអស់ពីដីរបស់ឈ្មោះ ម៉ិល សារឿន និង ឱ្យបង់សំណងជម្ងឺចិត្តចំនួន ៣.០០០.០០០រៀល " បីលានរៀល " ទៅឈ្មោះ ម៉ិល សារឿន ចាប់ពីពេលដែលសាលក្រមនេះចូលជាស្ថាពរ ។

៤- បង្គាប់ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ បង់ប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០រៀល ប្រាក់នេះ បានកាត់យកពីប្រាក់ដែលដើមចោទបាន បង់រួចហើយ ពេលសាលក្រមផុតបណ្ដឹងឧទ្ធរណ៍ ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ បង់សងវិញ ។

និង បង្គាប់ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ បង់ពន្ធសមាមាត្រចំនួនមួយភាគរយលើដីទំនាស់ស្មើ $\frac{\text{៤.២១២ម}^{២} \times \text{១,៥\$}}{\text{១០០}}$ = ៦៣,១៨ ដុល្លាអាមេរិក បន្ថែមទៀត ប្រាក់ពន្ធនេះត្រូវឱ្យដើមចោទបង់ទុកជាមុនផងដែរ ទើបបង្គាប់ ឱ្យចុងចម្លើយបង់សងវិញជាស្រេច ។

៥- សាលក្រមនេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកសិទ្ធិប្ដឹងទាស់ និង ប្ដឹងឧទ្ធរណ៍ តាមច្បាប់ ។

បានឃើញ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០១ របស់ លោក ប៊ូ ភិនសុវណ្ណ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៦០ " ខ " ចុះថ្ងៃទី ១៤ខែ មិថុនា ឆ្នាំ ២០០១ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញ សាលដីការរដ្ឋប្បវេណីលេខ ១៧៨ " ឈ " ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានសេចក្ដីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០១ របស់ឈ្មោះ ប៊ូ ភិនសុវណ្ណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តំកល់សាលក្រមរដ្ឋប្បវេណីលេខ ៦០ " ខ " ចុះថ្ងៃទី ១៤-៦-២០០១ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល ។

៣- កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ ១៣.០០០រៀល ដែលដើមបណ្ដឹងបានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រៀល ចំណាយលើអាជ្ញាចរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល ។

៤- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្ដឹងទាស់លេខ ០៦ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០២ របស់លោក ប៊ូ ភិនសុវណ្ណ ប្ដឹងទាស់នឹងសាលដីការរដ្ឋប្បវេណីលេខ ១៧៨ "ឈ " ចុះថ្ងៃទី ១៨-១២-២០០១ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

បានឃើញ សាលដីកាវដ្ឋប្បវេណីលេខ ៣១ " ឈ " ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី ១១-០១-២០០២ របស់ឈ្មោះ ប៊ូ ភិនសុវណ្ណ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២- តំកល់សាលដីកាកំបាំងមុខលេខ ១៧៨ "ឈ "ចុះថ្ងៃទី ១៨-១២-២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

៣- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០២ របស់លោកប៊ូ ភិនសុវណ្ណ ប្តឹងមិនសុខចិត្តនឹងសាលដីកាវដ្ឋប្បវេណីលេខ ៣១ " ឈ " ចុះថ្ងៃទី ០៧-០២-២០០២ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីកាវដ្ឋប្បវេណីលេខ ៥១ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ ២៤៤ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០២ របស់លោក ប៊ូ ភិនសុវណ្ណ ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាវដ្ឋប្បវេណីលេខ ៣១ " ឈ " ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងវដ្ឋប្បវេណីលេខ ២៩៤ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តី ដែលចុងចម្លើយ បានបង់នៅតុលាការកំពូលចំនួន ១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប១៩.០០០រៀល ហើយតំរូវឱ្យដើមចោទសងប្រាក់ចំនួន ១៩.០០០រៀល នេះទៅចុងចម្លើយវិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ។

បានឃើញ សាលដីកាវដ្ឋប្បវេណីលេខ ៣៩ " ឃ " ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ទទួលជំនុំជំរះ សំណុំរឿងលេខ ៣១ ចុះថ្ងៃទី ០២-៤-២០០៣ របស់សាលាឧទ្ធរណ៍ តាមអំណាចសាលដីការបស់តុលាការកំពូលលេខ ៥១ ចុះថ្ងៃទី១១-៣-២០០៣ យោងតាមបញ្ញត្តិមាត្រា១១ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព នៃ សាលាជំរះក្តី ។

២- ទទួលស្គាល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព.០០៩៥៥ ចុះថ្ងៃទី ២១-៨-១៩៩៨ របស់ឈ្មោះ ម៉ិល សារឿន និង នាង មាស ណារី ទុកជាត្រឹមត្រូវតាមច្បាប់ ។ ប្រគល់ដីទំនាស់ទំហំ ៥៤ម ×៧៨ម ដែលមានក្នុងប័ណ្ណខាងលើ ឱ្យទៅឈ្មោះ ម៉ិល សារឿន កាន់កាប់តាមច្បាប់ ។

៣- បង្គាប់ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ រុះរើរោងចេញពីដីរបស់ ឈ្មោះ ម៉ិល សារឿន ចាប់ពីពេលសាលដីកានេះ ចូលជាស្ថាពរ ។

៤- បង្គាប់ឱ្យឈ្មោះ ប៊ូ ភិនសុវណ្ណ បង់ពន្ធសមាមាត្រ ១% លើតម្លៃដីទាស់ ។

៥- សាលដីកានេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ។ បើកផ្លូវប្តឹងសាទុក្ខលើកទី២ តាមកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលើកទី២លេខ ២៥៨ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៣ របស់លោក ប៊ូ ភិនសុវណ្ណ មិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៩ " ឃ " ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ លើគ្រប់ចំណុច នៃ សេចក្តីសំរេចទាំងមូល ។

បានឃើញ សាលដីការបៀបរដ្ឋប្បវេណីលេខ ២៦៦ ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០០៣ របស់តុលាការកំពូល ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១- ចាត់របៀបឱ្យធ្វើការស៊ើបសួរបន្ថែម

២- ក្នុងករណីចាំបាច់ ចាត់ចៅក្រមប្រឹក្សាតុលាការកំពូល ចុះពិនិត្យដល់ទីកន្លែងដីទំនាស់

៣- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០០៣ ។

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការបញ្ជាក់ថា :

- បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។
- សំណុំរឿងនេះដែរ តុលាការកំពូល ក៏បានចាត់របៀបរួចហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិនិត្យ និង សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់លោក ប៊ូ ភិនសុវណ្ណ ឆ្លើយថា : បានជាខ្លួនប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ព្រោះសាលាឧទ្ធរណ៍កាត់ក្តីដោយអយុត្តិធម៌ ។ ដីទំនាស់នេះ ខ្លួនបានកាន់កាប់ និង គ្រប់គ្រងតាំងពីឆ្នាំ ១៩៧៩មកម្លេះ ហើយដីនេះ ក៏ជាដីរបស់ដូនតាខ្លួនយូរលង់ណាស់មកហើយ ដីនេះក៏មានអាជ្ញាធរទទួលស្គាល់ដែរ ។ លោក ម៉ិល សារឿន បានឆ្លើយបំភ្លឺនៅតុលាការថ្នាក់ក្រោមមកនោះ គឺពុំត្រឹមត្រូវទេ ។ លោក ម៉ិល-

សារឿន និង ហ៊ុន ប៊ុនធឿន បានឃុបឃិតគ្នាយកឡានដឹកដីចាក់រំលោភបំពានយកដីរបស់ខ្លួន ។

សូមឱ្យតុលាការជួយវែកញែក រកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់លោក ម៉ិល សារឿន ឆ្លើយថា : បញ្ហាដីទំនាស់នេះ ខ្លួនបានទិញពីលោក ហ៊ុន ប៊ុនធឿន មានលិខិតស្នាមត្រឹមត្រូវ ហើយដល់ចុងឆ្នាំ ៩៨ ខាងមន្ទីរសុរិយោដីក្រុងភ្នំពេញ បានចេញលិខិតលេខ ០០៩៥៥ ចុះថ្ងៃទី២១-៨-៩៨ ប្រគល់ឱ្យខ្លួនកាន់កាប់ ។ រយៈពេលជាង ១ឆ្នាំ ក្រោយមក ទើបលោក សុវណ្ណ មកសង់ខ្ទមលើដីទំនាស់នេះ ហើយខ្លួនក៏សួរគាត់ថា ហេតុអ្វីបានជាមកសង់ខ្ទមលើដីនេះ លោក សុវណ្ណ ឆ្លើយថា : មកពីលោក ហ៊ុន ប៊ុនធឿន ពុំទាន់ប្រគល់លុយឱ្យគ្រប់ចំនួន ។ ហើយខ្លួនក៏បានទៅសួរ លោក ហ៊ុន ប៊ុនធឿន ដែលបានលក់ដីឱ្យខ្លួននេះ គាត់ថា ពុំបានទិញដីពីលោក ប៊ូ ភិនសុវណ្ណ ទេ គឺទិញដី ពីលោក ទុយ សេង , លោក សោម-សាមិន , លោក ប៊ិន ថា , លោក អ៊ុក ឡៃ ។ នៅពេលដែលខ្លួនទិញដីបានហើយនោះ ខ្លួនក៏ដាំបង្គោលរបង និងចាក់ដី ប្រហែល ៩០% ទុកតែប្រលោះខ្ទមតូចនោះទេ ដីនេះខ្លួនបានចាក់ដីជាង ១ហិកតា រួចហើយ ពេលមុនចាក់ដីខ្លួនបានដាំត្រកួន ឈូក ... ប៉ុន្តែលោក សុវណ្ណ ពុំដែលមកទាមទារអ្វីទេ ។ បានជាខ្លួនមិនចាក់ដីលើខ្ទមរបស់លោក សុវណ្ណ នោះ ព្រោះខ្លួនយល់ថា ប្រទេសយើងមានច្បាប់ទំលាប់ត្រឹមត្រូវ ហើយពេលខ្លួនចាក់ដីនេះ លោក សុវណ្ណ ពុំបានហាមឃាត់ រឺ រករឿងអ្វីទេ ចំណែកដីរបស់លោក ទុយ សេង ខ្លួនទិញតែ ១ផ្នែកទេ ផ្នែកផ្សេងទៀត គេជាអ្នកទិញទេ ។

បានស្តាប់ចម្លើយរបស់លោក ប៊ូ ភិនសុវណ្ណ ឆ្លើយថា : ដីនេះ ខ្លួនបានកាន់កាប់គ្រប់គ្រងរហូតមក ហើយខ្លួនក៏ពុំបានទាក់ទងអ្វីជាមួយលោក ម៉ិល សារឿន ដែរ ពេលចាក់ដីខ្លួនពុំបានឃាត់គាត់មែន ប៉ុន្តែខ្លួនមានឯកសារត្រឹមត្រូវ ហើយខ្លួននិយាយនេះ សុទ្ធតែពាក្យពិត ហើយក៏ពុំបានទិញឯកសារពីបុគ្គលណាទេ ។ ខ្លួនមានដីប្រវែងបណ្តោយ ២៨០ម និង ទទឹង ១៦៣ម ហើយដីដែលលោក ម៉ិល សារឿន ធ្វើរបងរំលោភចូលដីខ្លួនប្រហែល ៥៦ម ×៧៨ម ចំណែកដីដែលខ្លួនបានលក់ឱ្យលោក ហ៊ុន ប៊ុនធឿន មានទំហំ ៧៨ម × ២៨០ម ហើយលោក ហ៊ុន ប៊ុនធឿន បានលក់ឱ្យលោក ម៉ិល សារឿន បន្ត ទំហំតែ ៥៦ម × ៧៨ម ។

បានស្តាប់លោក កែវ យ៉ា ជាមេធាវី បានឡើងសុំក្រុមប្រឹក្សាជំនុំជំរះ ដើម្បីសុំសួរសំនួរទៅលោក ប៊ូ ភិនសុវណ្ណ ថា តើដីដែលលោក ប៊ូ ភិនសុវណ្ណ បានលើកឡើងនេះ មានទំហំប៉ុន្មាន ហើយខាងជើងមានប៉ុន្មាន-ខាងត្បូងមានប៉ុន្មាន ? និង តើលោក សុវណ្ណ បានដីពីណាមក បើនៅពេលលោក ហ៊ុន ប៊ុនធឿន លើកផ្លូវដល់ទៅ ១០ម ឯណោះ ?

បានស្តាប់ចម្លើយរបស់លោក ប៊ូ ភិនសុវណ្ណ ឆ្លើយបញ្ជាក់ថា : ដីដែលខ្លួនបានគ្រប់គ្រងទាំងអស់ គឺ បណ្តោយ ២៨០ម និង ទទឹង ១៦៣ម ។ ក្នុងប្រវែង ទទឹង ១៦៣មនេះដែរ គឺ បានចែកខ័ណ្ឌជាពីរ ដែលមានខាងជើងមានទំហំ ៧៨ម និង ខាងត្បូងមានទំហំ ៨៥ម ។

ចំណែកឯដីលើកផ្លូវ ១០ម នោះ គឺជាដីរបស់ខ្លួន ដែលធ្វើលើដីទំហំ បណ្តោយ ២៨០ម និង ទទឹង ១៦៣ម ហើយដីនេះជាដីបឹង ។ ដីទំនាស់មានទំហំ ៧៨ម × ៥៦ម ក្នុងដីទំហំ បណ្តោយ ២៨០ម និង ទទឹង ១៦៣ម ។ ដីសល់ពីដីទំនាស់នេះ គឺខ្លួនជាអ្នកគ្រប់គ្រងទាំងអស់ ហើយខ្លួនបានជាឈ្នួក ត្រកូន រហូតមក ចំណែកអាជ្ញាធរមូលដ្ឋានឃុបឃិតគ្នា រំលោភយកដីរបស់ខ្លួន ដូចនេះ គេម្តេចនឹងហ៊ានឆ្លើយថា ឃើញខ្លួននៅទីនោះទៅ ។ ដីដែលមានព្រំប្រទល់ខាងជើង ទល់ដី ឌុយ សេង និង ខាងត្បូងទល់ដី សោម សាមិន គឺមិនជាន់លើដីរបស់ខ្លួនទេ ។ ខ្លួនបានលក់ដីឱ្យ លោក ហ៊ុន ប៊ុនធឿន មែន ប៉ុន្តែគេពុំទាន់ប្រគល់លុយឱ្យខ្លួនគ្រប់ចំនួនទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក កែវ យ៉ា ជាមេធាវីឱ្យដើមចោទ បញ្ជាក់ថា :

ដីរបស់កូនក្តីខ្លួន បានទិញពីលោក ហ៊ុន ប៊ុនធឿន និង ប្រគល់លុយឱ្យគ្រប់ចំនួនរួចអស់ហើយ ហើយក៏បានសុំសិទ្ធិកាន់កាប់រួចអស់ហើយដែរ ។ ហើយមុនចុះវាស់វែងក៏បានបិទប្រកាស ស្តីពីការ ចុះបញ្ជីកាន់កាប់ដី ហើយដែរ តែគ្មានឃើញអ្នកណាមកប្តឹងរឺ រករឿងអ្វីឡើយ ។ លោក ហ៊ុន ប៊ុនធឿន ក៏បានអះអាងដែរថា គាត់ទិញដីពីលោក សោម សាមិន , ឌុយ សេង , ប៊ិន ថា , អ៊ុក ឡៃ ទេ ពុំមែនទិញពីលោក សុវណ្ណ ទេ ហើយអ្នកទាំងបួនក៏បានបញ្ជាក់ដែរថា គាត់ក៏បានកាន់កាប់រហូតមកតាំងពីឆ្នាំ ១៩៧៩ មកម្លេះ ។ ហើយពួកគាត់ទាំងបួនថា ពួកគាត់ពិតជាបានលក់ដីឱ្យលោក ហ៊ុន ប៊ុនធឿន ហើយគាត់បានលើកផ្លូវកាត់ចំពាក់កណ្តាលព្រៃ ហើយគាត់ក៏ពុំបានលើកផ្លូវលើដីរបស់លោក សុវណ្ណ ដែរ ។ ចំណែក លោក ម៉ុល សារឿន បានទិញដីពី លោក ហ៊ុន ប៊ុនធឿន ពិតប្រាកដមែន ដោយមានអាជ្ញាធរមូលដ្ឋានទទួលដឹងឮ និង បានបញ្ជាក់ថា លោក ម៉ុល សារឿន ពិតជាបានទិញដីពីលោក ហ៊ុន ប៊ុនធឿន មែន ព្រោះលោក ប៊ូ ភិនសុវណ្ណ និង ប្រពន្ធ បានទទួលដី ១ឡូត៍ ទំហំ ២៥ម × ៣០ម ពីប្រធានក្រុមប្រគល់ឱ្យ លើសពីដីនេះ តើគាត់បានមកពីណា ? ។ សាក្សីខ្លះបញ្ជាក់ថា លោក ប៊ូ ភិនសុវណ្ណ ពិតជាបានលក់ដីឱ្យលោក ហ៊ុន ប៊ុនធឿន មែន ហើយមិនទាន់ប្រគល់លុយឱ្យគ្រប់ចំនួននោះ ជាដីពោងពាយទេ មិនមែនជាដីនៅម្តុំបឹងបាយ៉ាបទេ ។ ចំណែករដ្ឋអំណាចមូលដ្ឋានបានបញ្ជាក់ថា ដីទំនាស់នេះ គឺជាដីរបស់លោក ឌុយ សេង អ៊ុក ឡៃ , សោម សាមិន , ប៊ិន ថា មិនមែនរបស់លោក ប៊ូ ភិនសុវណ្ណ ទេ ។ បើសិនជាបូកដីនេះ ទៅឃើញដល់ទៅ ១៧០ម ជាង ហើយគាត់ថា តែ ១៦៣ម ទេ ប្រវែងទទឹង ។

សូមលោក តុលាការ មេត្តាឱ្យ លោក ប៊ូ ភិនសុវណ្ណ រុះរើផ្ទះចេញ ពីដីទំនាស់នេះ ។

សូមលោក តុលាការ មេត្តាប្រគល់ដីនេះ មកឱ្យកូនក្តីរបស់ខ្លួន បានគ្រប់គ្រង កាន់កាប់តទៅ ។

បានស្តាប់ចម្លើយរបស់លោក ប៊ូ ភិនសុវណ្ណ បានឆ្លើយបន្ថែមទៀតថា : ដីនេះ ជាដីរបស់ខ្លួនពិតប្រាកដមែន ហើយខ្លួនក៏មានឯកសារត្រឹមត្រូវដែរ ចំណែកការលក់ដូររបស់គេនោះ គឺសុទ្ធតែមិនពិត ហើយបានឃុបឃិតគ្នារំលោភយកដីរបស់ខ្លួនទាំងអស់ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយគូភាគី និង សេចក្តីសន្និដ្ឋាន ការពាររបស់មេធាវីដើមចោទ.
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥៨ ចុះថ្ងៃទី ៣០-០៦-០៣ របស់ឈ្មោះ ប៊ូ ភិនសុវណ្ណ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាច លើករឿងនេះ មកធ្វើការជំនុំជំរះរួមក្រុម បានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណី បានផងដែរ ។

- យល់ឃើញថា ដីទំនាស់ដែលមានទំហំ ៥៦ម ×៨៧ម ស្ថិតនៅក្នុងមូលដ្ឋានភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ជាប្រភេទដីបឹង ដែលកាលពីមុនដីបឹងនេះ ត្រូវបានប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានចូលធ្វើការកាន់កាប់បង្កបង្កើនផលដំណាំឈូក ។ ការចូលកាន់កាប់នេះ ពុំមានការរារាំងពីរដ្ឋអំណាចមូលដ្ឋានឡើយ ហើយក៏ពុំមានការផ្តល់សិទ្ធិកាន់កាប់ឱ្យប្រជាពលរដ្ឋ តាមរយៈឯកសារជាផ្លូវការដែរ ។ ភាគីនីមួយៗ អាចធ្វើការអះអាងសិទ្ធិរបស់ខ្លួន ចំពោះការតតាំងនានាបានតាមរយៈការដឹងឮរបស់សាក្សី ដែលជាម្ចាស់ដីមានទីតាំងនៅជាប់ព្រំគ្នា និង ការបញ្ជាក់របស់សមត្ថកិច្ចមូលដ្ឋានប៉ុណ្ណោះ ។

- យល់ឃើញថា មានភស្តុតាងបញ្ជាក់ថា ដីទំនាស់ដែលឈ្មោះ ប៊ូ ភិនសុវណ្ណ អះអាងថា ជាដីរបស់ខ្លួននោះ គឺជាន់ចំលើដី ដែលមានម្ចាស់ដើមឈ្មោះ ឌុយ សេង , អ៊ុក ឡៃ និង ប៊ិន ថា លក់ឱ្យឈ្មោះ ហ៊ុន ប៊ុនធឿន ហើយឈ្មោះ ហ៊ុន ប៊ុនធឿន លក់បន្តឱ្យឈ្មោះ ម៉ុល សារឿន នៅក្នុងខែ កក្កដា ឆ្នាំ១៩៩៨ ដែលទំនាក់ទំនងនៃការទិញ-លក់ រវាងឈ្មោះ ហ៊ុន ប៊ុនធឿន និង ឈ្មោះ ឌុយ សេង , ប៊ិន ថា , អ៊ុក ឡៃ ក៏ដូចជាការទិញ-លក់ រវាង ហ៊ុន ប៊ុនធឿន និង ភាគី ម៉ុល សារឿន មានកិច្ចសន្យាលាយលក្ខណ៍អក្សរ មានការបញ្ជាក់របស់មន្ត្រីសមត្ថកិច្ចមូលដ្ឋាន នៃ ទីតាំងដីទំនាស់ត្រឹមត្រូវ ហើយក៏ពុំមានវិការៈដែលគួរសង្ស័យថា លោកឌុយ សេង ប៊ិន ថា , អ៊ុក ឡៃ ពុំមែនជាម្ចាស់ដីឡើយ ដោយហេតុថា ពួកលោក គឺជាប្រជាពលរដ្ឋក្នុងមូលដ្ឋានដីទំនាស់ ដែលត្រូវតែដឹងច្បាស់ពីទីតាំងដីរបស់ខ្លួន និង ម្យ៉ាងទៀតមានសាក្សីដឹងឮពីសិទ្ធិភោគៈនេះ រីឯខាងលោក ប៊ូ ភិនសុវណ្ណ ពុំមែនជាពលរដ្ឋក្នុងមូលដ្ឋាននេះឡើយ ហើយក៏ពុំមានឯកសារភស្តុតាង ដែលបញ្ជាក់ពីសិទ្ធិភោគៈរបស់ខ្លួនលើដីទំនាស់ឡើយ ការបំភ្លឺរបស់សាក្សីចុងចម្លើយនេះ មានភាពមិនប្រាកដប្រជា និង សាក្សីខ្លះបានឆ្លើយ ផ្តល់ប្រយោជន៍

ឱ្យដើមចោទ ។

- យល់ឃើញថា មានសំអាងច្បាស់ថា លោក ម៉ិល សារឿន បានលទ្ធកម្មកម្មសិទ្ធិលើដីទំនាស់នេះ ត្រឹមត្រូវតាមច្បាប់រួចហើយ ដោយហេតុថា ក្រោយពីមានកិច្ចសន្យា ទិញ-លក់ ដោយមានការដឹងឮ ពីរដ្ឋអំណាចមូលដ្ឋានផងនោះ លោក ម៉ិល សារឿន និង លោកស្រី មាស ណារី បានចូលកាន់កាប់ដីដោយសុច្ចរិត ដោយមានធ្វើរបងចាក់ដី និង បានបង់ពន្ធដីជូនរដ្ឋ ហើយបានទទួលប័ណ្ណសំគាល់សិទ្ធិ កាន់កាប់អចលនវត្ថុលេខ ភព ០០៩៥៥ ចុះថ្ងៃទី ២១-០៨-៩៨ របស់មន្ទីរសុរិយោដីរាជធានីភ្នំពេញ ដែលជាសមត្ថកិច្ចជំនាញ ហើយទើបតែមានការតវ៉ាពីសំណាក់លោក ប៊ូ ភិនសុវណ្ណ នៅដើមឆ្នាំ ២០០០ ប៉ុណ្ណោះ ។

- យល់ឃើញថា លោក ប៊ូ ភិនសុវណ្ណ បានឆ្លើយនៅក្នុងកំណត់ហេតុ ចុះថ្ងៃទី ០៦-០១-០៤ នៅតុលាការកំពូល និង នៅពេលសវនាការនេះថា ដីរបស់ លោក ខាងជើងជាប់ព្រំប្រទល់នឹង លោក ឱ្យយ សេង ខាងកើតជាប់នឹងព្រំប្រទល់ លោក សោម សាមិន មិនជាន់លើដីរបស់ លោក ឱ្យយ សេង និង លោក សោម សាមិនទេ។ ដូច្នេះ បញ្ជាក់ថា ការដែលលោក ប៊ូ ភិនសុវណ្ណ បានចង្អុលបង្ហាញទំហំដី នៅក្នុងគំនូសប្លង់ ចុះថ្ងៃទី ២៧-២-២០០៤ របស់ចៅក្រមតុលាការកំពូល ជាការពុំត្រឹមត្រូវទេ ពីព្រោះការចង្អុលបង្ហាញនេះ គឺហួសពីដី ឱ្យយ សេង ទៅដល់ដី អ៊ុក ឡៃ និង ប៊ិន ថា ហើយខាងកើតដែលថា ទល់ សោម សាមិន គឺត្រូវរំលងដីអ៊ុក ឡៃ , ប៊ិន ថា និង ឱ្យយ-សេង ។

- យល់ឃើញថា សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីឡើងវិញ តាមសាលដីការដ្ឋប្បវេណីលេខ ៣៩ " ឃ " ចុះថ្ងៃទី ១៩-០៦-០៣ នោះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី ចំពោះមុខក្តី

១- ទទួលបណ្តឹងសាទុក្ខលើកទី២ លេខ ២៩៨ ចុះថ្ងៃទី ៣០-០៦-០៣ របស់ឈ្មោះ ប៊ូ ភិនសុវណ្ណ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៩ " ឃ " ចុះថ្ងៃទី ១៩-០៦-០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តី ដែលលោកម៉ិល សារឿន បានបង់នៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០រៀល សំរាប់

ជារង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.000រៀល សរុប ១៩.000រៀល ហើយតំរូវឱ្យលោក ប៊ូ ភិនសុវណ្ណ សងប្រាក់ចំនួន ១៩.000រៀល នេះ ទៅ លោក ម៉ុល សារឿន វិញ ។

បង្គាប់ឱ្យលោក ប៊ូ ភិនសុវណ្ណ បង់ពន្ធសមាមាត្រ ១% លើតម្លៃដីទំនាស់ ។

៤- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៤ ។